អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែកក្កដា

លេខ ៣១/២៤ ចេញផ្សាយ ខែកក្កដា ឆ្នាំ២០២៤

## គោលបំណងនៃការរៀបចំផែនការថវិកា

ការរៀបចំផែនការថវិកា គឺមានគោលបំណងក្នុងការផ្សារភ្ជាប់ថវិកាទៅនឹងគោលដៅអាទិភាព របស់ស្ថាប័ន ដើម្បីធានាអោយបាននូវការគ្រប់គ្រង និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព។ ការរៀបចំផែនការថវិកាផ្តល់នូវមូលដ្ឋានដល់ការរៀបចំថវិកាកម្មវិធី ហើយជាឧបករណ៏សម្រាប់ការធ្វើសមាហរណកម្មថវិការវាងថវិកាចរន្ត និងថវិកាមូលធន។

**១. ការព្យាករណ៍នៃការអនុវត្តចំណូល និងការអនុវត្តចំណាយ (ដើម្បីរកផលចំណេញ)**

ថវិកាគឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការរៀបចំផែនការរបស់ស្ថាប័ន និងជាមូលដ្ឋានសម្រាប់ឱ្យស្ថាប័នអាចដំណើរការបានដោយរលូនទៅលើផ្នែកហិរញ្ញវត្ថុ ប្រសិនបើយុទ្ធសាស្រ្តនិងផែនការជាក់លាក់ត្រូវអនុវត្ត។ ក្នុងការរៀបចំផែនការថវិកាស្ថាប័នត្រូវតែព្យាករណ៏ចំណូល និងចំណាយ ដោយមានមូលដ្ឋានច្បាស់លាស់។



**២. ឧបករណ៍សម្រាប់ធ្វើការសម្រេចចិត្ត**

គោលបំណងនៃការរៀបចំផែនការថវិកា គឺដើម្បីផ្តល់នូវក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ដំណើរការធ្វើការសម្រេចចិត្ត ពោលគឺជាសម្មភាពដែលបានស្នើឡើង ឬអ្វីមួយដែលស្ថាប័នបានគ្រោងទុក។ ក្នុងការគ្រប់គ្រងស្ថាប័នប្រកបដោយទំនួលខុសត្រូវ ការចំណាយត្រូវតែគ្រប់គ្រងយ៉ាងម៉ត់ចត់។ ឧទាហរណ៏÷ នៅពេលដែលស្ថាប័នគ្រោងមានការចំណាយរៀបចំសិក្ខាសាលា ការសម្រេចចិត្ត “**តើស្ថាប័នគួរតែរៀបចំសិក្ខាសាលាតាមមធ្យោបាយណាដែលនាំអោយមានការចំណាយប្រកបដោយភាពសន្សំសំចៃបំផុត**”។




**៣. មធ្យោបាយត្រួតពិនិត្យដំណើរការរបស់ស្ថាប័ន**

ថវិកាក្លាយជាមូលដ្ឋានដែលស្ថាប័នប្រើប្រាស់ដើម្បីត្រួតពិនិត្យ។ ស្ថាប័នអាចដឹងថា តើការចំណាយរបស់ខ្លួនគឺបានត្រឹមត្រូវឬទេ មានន័យថាចំណាយដែលបានអនុវត្តគឺមានក្នុងថវិកា។

អត្ថបទ÷ លោក **សុខ តិចឡាយ**

**ឯកសារយោង÷** ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.**

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

Facebook Telegram Website